# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

លេខ [illegible] សហវ.-[illegible]

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥

## ជម្រាបជូន
## ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ:** សេចក្តីណែនាំបន្ថែមស្តីពីការរៀបចំគម្រោងថវិកាចំណាយបន្ទុកបុគ្គលិក (ជំពូក៦៤) ឆ្នាំ២០១៦។

**យោង:** ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ លើលិខិតរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីរបាយការណ៍ចំណាយបុគ្គលិកនៅស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងវិធានការកែទម្រង់បៀវត្សសម្រាប់រយៈពេល ២០១៦-២០១៨ និងសំណើសុំការពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់លើវិធានការផ្សេងៗសម្រាប់ការដាក់អនុវត្តគម្រោងដំឡើងបៀវត្សក្នុងរបាយការណ៍។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំបន្ថែមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំគម្រោងថវិកាបន្ទុកបុគ្គលិក (ជំពូក៦៤) ឆ្នាំ២០១៦ ដូចខាងក្រោម៖

១. ក្របខណ្ឌនៃការដំឡើងបៀវត្ស និងចំណាយបន្ទុកបុគ្គលិក សម្រាប់ឆ្នាំ២០១៦

- ដំឡើងបៀវត្សមូលដ្ឋាន ក្នុងអត្រា ១២% ដោយអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៦ ទៅ សម្រាប់មន្ត្រីរាជការទាំងអស់
- ដំឡើងប្រាក់បំណាច់មុខងារសម្រាប់មន្ត្រីរាជការទាំងអស់ អនុវត្តចាប់ពីខែមេសា ឆ្នាំ២០១៦ ទៅ ដែលក្នុងនោះប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល នឹងត្រូវដំឡើងសម្រាប់អ្នកទទួលបានចាប់ពីក្រោម ៥០០ ០០០ រៀល ក្នុង ១ ខែ ដោយប្រាក់បំណាច់មុខងារទាបបំផុតនឹងត្រូវដំឡើងពី ១៥០ ០០០ រៀល ក្នុង ១ ខែ ដល់ ២៥០ ០០០ រៀល ក្នុង ១ ខែ
- ចំនួនមន្ត្រីជាប់កិច្ចសន្យាត្រូវរក្សាក្នុងចំនួនដែលប្រើប្រាស់បច្ចុប្បន្ន និងដំឡើងប្រាក់ឧបត្ថម្ភ ៤០០ ០០០ រៀល ក្នុង ១ ខែ ដោយអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៦
- ត្រូវគ្រោងដំឡើងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ ដោយចាប់អនុវត្តពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០១៦ តាមតារាងដូចខាងក្រោម៖

| រដ្ឋបាលថ្នាក់ក្រោមក្រោមជាតិ | មុខតំណែង | ប្រាក់ឧបត្ថម្ភ ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០១៦ (រៀល) |
|---|---|---|
| រាជធានី ខេត្ត | ប្រធានក្រុមប្រឹក្សា | ១ ០៥០ ០០០ |
| | សមាជិកក្រុមប្រឹក្សា | ៨៧០ ០០០ |
| ក្រុង ស្រុក ខណ្ឌ | ប្រធានក្រុមប្រឹក្សា | ៨១០ ០០០ |
| | សមាជិកក្រុមប្រឹក្សា | ៦៥០ ០០០ |
| ឃុំ សង្កាត់ | មេឃុំ ចៅសង្កាត់ | ៧៥០ ០០០ |
| | ជំទប់ទី១, ទី២ ចៅសង្កាត់រងទី១, ទី២ | ៥៥០ ០០០ |
| | សមាជិកក្រុមប្រឹក្សា | ៤៨០ ០០០ |
| ភូមិ | ប្រធានភូមិ | ២០០ ០០០ |
| | អនុប្រធានភូមិ | ១៦០ ០០០ |
| | សមាជិកភូមិ | ១៤០ ០០០ |



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ Phone : 855-23-724 664
ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨ Fax: 855-23-427 798

២.វិធាននៃការគ្រោងដំឡើងថវិកា ប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា

- រដ្ឋបាលក្រុង ស្រុក ត្រូវគ្រោងតាមវិធានដូចខាងក្រោម៖
  - គ្រោងចំណាយមិនបានគ្រោងទុក ៥% នៃកញ្ចប់សរុបរបស់ក្រុង ស្រុកនីមួយៗ
  - គ្រោងបន្ទុកបុគ្គលិក (ជំពូក៦៤) ក្នុងនោះត្រូវគ្រោងសម្រាប់ទូទាត់បុរេប្រទានចំណាយបន្ទុកបុគ្គលិកដែលបានខ្វះឥណទានក្នុងឆ្នាំ២០១៥ និងគ្រោងចំណាយបន្ទុកបុគ្គលិកជាក់ស្តែងឆ្នាំ២០១៦ ផ្អែកលើក្របខណ្ឌដំឡើងថវិកាឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល
  - ចំណាយរដ្ឋបាលសុទ្ធសាធស្មើនឹង ២៥% នៃកញ្ចប់មូលនិធិសរុប (ពុំមានចំណូលពីការផ្តល់សេវារដ្ឋបាល) *ដក* ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនបានគ្រោងទុក
  - តួលេខដែលនៅសល់ពីផលដកខាងលើ ត្រូវគ្រោងសម្រាប់ចំណាយអភិវឌ្ឍមូលដ្ឋាន
  - ចំណូលពិត (ចំណូលសរុបពីការផ្តល់សេវារដ្ឋបាល *ដក* ចំណែកប្រាក់រង្វាន់) អាចគ្រោងសម្រាប់រ៉ាប់រងចំណាយប្រតិបត្តិការរដ្ឋបាល ឬ ចំណាយអភិវឌ្ឍមូលដ្ឋាន តាមតម្រូវការជាក់ស្តែង
- រដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រោងតាមវិធានដូចខាងក្រោម៖
  - ការគ្រោងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សានិងមន្ត្រីភូមិ (ជំពូក៦៤) ត្រូវគ្រោង: (១)សម្រាប់ទូទាត់បុរេប្រទានចំណាយប្រាក់ឧបត្ថម្ភក្រុមប្រឹក្សានិងមន្ត្រីភូមិដែលបានខ្វះឥណទានក្នុងឆ្នាំ២០១៥ (២)គ្រោងចំណាយប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាជាក់ស្តែងឆ្នាំ២០១៦ ស្របតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន និង(៣)គ្រោងសម្រាប់ការដំឡើងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សានិងមន្ត្រីភូមិក្នុងឆ្នាំ២០១៦ ផ្អែកលើក្របខណ្ឌដំឡើងថវិកាឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល
  - ចំណាយប្រតិបត្តិការរដ្ឋបាល ស្មើនឹង ១៥% នៃធនធានមូលនិធិឃុំ សង្កាត់នីមួយៗសរុប *ដក* ចំណាយសរុបប្រាក់ឧបត្ថម្ភក្រុមប្រឹក្សានិងមន្ត្រីភូមិ (ជំពូក៦៤)
  - ចំណាយអភិវឌ្ឍមូលដ្ឋាន ស្មើនឹងធនធានមូលនិធិឃុំ សង្កាត់នីមួយៗសរុប *ដក* ចំណាយសរុបប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់និងមន្ត្រីភូមិ និងចំណាយសរុបសម្រាប់ប្រតិបត្តិការរដ្ឋបាល

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាផ្សព្វផ្សាយសេចក្តីណែនាំបន្ថែមនេះ ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់អនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

សូម ឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានពីខ្ញុំ

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- អគ្គនាយកដ្ឋានរតនាគារជាតិ
  "ដើម្បីជូនជ្រាប"
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ